# បេឡាជាតិរបបសន្តិសុខសង្គម

## National Social Security Fund

ប.ស.ស ឆ្នាំទី៦ ឆ្នាំ២០១៦

ព្រឹត្តិបត្រព័ត៌មាន

១៥









ធានាសន្តិសុខប្រាក់ចំណូល

រួមចំណែកកាត់បន្ថយភាពក្រីក្រ

លើកកំពស់ស្ថិរភាពសង្គម

អ្នកមានជួយអ្នកក្រ

អ្នកមានសុខភាពល្អ ជួយអ្នកឈឺ

Hotline 24h/7

សេវាសង្គ្រោះបន្ទាន់

១២៨៦

# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- របាយការណ៍ / រចនាសម្ព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម.....................................................១
២- មួកសុវត្ថិភាពចំនួន ១,០០០មួក ត្រូវបានចែកជូនបងប្អូនកម្មករនិយោជិតនៅសាលាស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ...................................................................២
៣- ពិធីផ្សព្វផ្សាយអប់រំអំពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងផ្តល់ប័ណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត .....................................................៤
៤- ពិធីចែកប័ណ្ណបើកបរដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ CARLINTON (CAMBODIA) CO.,LTD ស្រុកជើងព្រៃ ខេត្តកំពង់ចាម .........................................៥
៥- ក្រុមការងារ ស.ជ.ក បានរៀបចំពិធីផ្តល់ប័ណ្ណបើកបរ និងផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ QUINT MAJOR INDUSTRIL CO.,LTD ........................................................................៧
៦- សិក្ខាសាលាលក្ខណៈទ្វេតំបន់ ស្តីពីគោលនយោបាយហិរញ្ញប្បទានសុខភាពសម្រាប់ការឈានឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកលនៅអាស៊ី ..............................៩
៧- កិច្ចប្រជុំផ្សព្វផ្សាយអំពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ នៅរោងចក្រ GOLDFAME STAR ENTERPRISES (CAMBODIA) LIMITED ............................១០
៨- កម្មការិនីនៅរោងចក្រ GRAND EAST FOODWEAR INT'L CORP សន្លប់ ៨៩នាក់ ផ្តើមចេញពីកម្មការិនីម្នាក់មានអាការៈមិនស្រួលខ្លួនបានសន្លប់ បន្ទាប់មកកម្មការិនីផ្សេងទៀតភិតភ័យសន្លប់តៗគ្នា .....................................................................១១
៩- កម្មករ-កម្មការិនីប្រមាណ ៣៣នាក់ ទទួលរងគ្រោះថ្នាក់ចរាចរណ៍បង្កដោយរថយន្តដឹកកម្មករបានគេចរថយន្តដឹកថ្ម ដែលបើកឆ្លងផ្លូវក្នុងល្បឿនលឿនបណ្តាលឱ្យក្រឡាប់ចាក់កម្មករទៅលើផ្លូវ ............................................................................១២
១០- បុរសម្នាក់ជិះម៉ូតូចេញពីធ្វើការបានជ្រុលចង្កូតទៅបុកជាមួយរថយន្តដឹកកម្មករបណ្តាលឱ្យរងរបួសជាច់រលៀកជង្គងខាងឆ្វេង .................................................១៣
១១- យ៉ាងហោចណាស់កម្មការិនី ១២នាក់ បានរងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍រវាងរថយន្តដឹកកម្មករ២គ្រឿងបុកគ្នានៅខេត្តស្វាយរៀង ...................................១៤
១២- ប្រកាស ស្តីពីតារាងកាលិកថែទាំសុខភាព ...................................................១៥
១៣- តារាងប្រាក់ឈ្នួលជាប់ភាគទានឧបសម្ព័ន្ធ១ ............................................២៣
១៤- តារាងកាលិកព្យាបាលវេជ្ជសាស្ត្រ និងថែទាំសុខភាពឧបសម្ព័ន្ធ២ ..........................២៤
១៥- ទស្សនគ្គរពិចារណា ...............................................................................២៧
១៦- ក្រុមប្រចាំការ HOTLINE 24 ម៉ោង......................................................២៨
១៧- អាហារសុខភាព ...................................................................................២៩
១៨- សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត...................................................៣០
១៩- បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.......................៣៤
២០- លិខិតអនុញ្ញាតបន្តអាជ្ញាប័ណ្ណបោះពុម្ពផ្សាយព្រឹត្តិបត្រ .......................................៣៨






## រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លេខានិពន្ធ លោកស្រី សុខ សុរ្យាស្មី

កញ្ញា យ៉ែម ចន្ទូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

លោក សុខ សុផល

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# មួកសុវត្ថិភាពចំនួន ១,០០០មួក ត្រូវបានចែកជូនបងប្អូនកម្មករនិយោជិត នៅសាលាស្រុកស្វាយអន្ទរ ខេត្តព្រៃវែង

បេឡាជាតិរបបសន្តិសុខសង្គម គឺជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកផ្សព្វផ្សាយអប់រំ អំពីសុវត្ថិភាពចរាចរណ៍ក្នុងពេលធ្វើដំណើររបស់កម្មករ និងអ្នកបើកបរដឹកកម្មករនិយោជិត ដោយផ្អែកតាមគោលការណ៍ របស់ក្រសួងមហាផ្ទៃ និងគណៈកម្មការ (គ.ស.ច.គ) ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅលើដងផ្លូវដែលកើតមានជារៀងរាល់ថ្ងៃ។



លោកអភិបាលស្រុកស្វាយអន្ទរ អញ្ជើញថ្លែងសុន្ទរកថាស្វាគមន៍ក្នុងអង្គពិធី



ឯកឧត្តម យុន ឈុន្នី អញ្ជើញជាអធិបតីក្នុងពិធីផ្តល់មួកសុវត្ថិភាពជូនកម្មករ

ជាមួយគ្នានេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានសហការជាមួយក្រសួងមហាផ្ទៃ និងសាលាស្រុកស្វាយអន្ទរ បានរៀបចំពិធីផ្សព្វផ្សាយអប់រំស្តីពី "សុវត្ថិភាពចរាចរណ៍ផ្លូវគោក និងចែកមួកសុវត្ថិភាព" ជូនដល់កម្មករនិយោជិត និងអ្នកបើកបរដឹកកម្មករ នៅសាលាស្រុកស្វាយអន្ទរ កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៦ ក្នុងភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ **ឯកឧត្តម យុន ឈុន្នី** អនុរដ្ឋលេខាធិការ តំណាង **សម្តេចក្រឡាហោម ស ខេង** បានអញ្ជើញជាអធិបតី ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរោងចក្រ កម្មករនិយោជិត និងអ្នកបើកបរដឹកកម្មករសរុបប្រមាណ ១,០០០នាក់។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តម យុន ឈុន្នី** បានអំពាវនាវ ដល់កម្មករ និងអ្នកបើកបរពេលធ្វើដំណើរទៅមក សូមមានការប្រុងប្រយ័ត្នជាប់ជានិច្ច ព្រោះអាយុជីវិតមិនអាចរកទិញបានទេ។ លោកក៏បានស្នើឱ្យទៅរៀនបើកបរ និងប្រឡងយកប័ណ្ណបើកបរឱ្យបានគ្រប់ៗគ្នា។





សិក្ខាកាមដែលជាកម្មករនិយោជិតចូលរួមក្នុងអង្គពិធី

ដោយមាន **លោក ជាវ ប៊ុនរិទ្ធ** ប្រធានការិយាល័យគោលនយោបាយតំណាង **លោក អ៊ុក សមវិទ្យា** នាយកបេឡាជាតិរបបសន្តិសុខសង្គម ដែលបានខិតខំប្រឹងប្រែងផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក និងកាត់បន្ថយឱ្យស្ថិតក្នុងកំរិតអប្បរមា។

ក្នុងឱកាសនេះដែរ **ឯកឧត្តម** ក៏បានលើកឡើងពីបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាជារៀងរាល់ថ្ងៃ ដោយគិតជាមធ្យមក្នុង១ថ្ងៃ មានចំនួនអ្នកស្លាប់ ០៦នាក់ និងរងរបួសជាច្រើននាក់ផ្សេងទៀត ព្រមទាំងបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ រួមមានម៉ូតូ និងរថយន្តជាច្រើនគ្រឿងទៀតផងដែរ។



ពិធីផ្តល់ប័ណ្ណសរសើរ

ក្រសួងមហាផ្ទៃ ក៏បានធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បេឡាជាតិរបបសន្តិសុខសង្គម ដែលបានឧបត្ថម្ភមួកស្តង់ដារសុវត្ថិភាពចំនួន ១,០០០មួក និងផ្តល់លិខិតថ្លែងអំណរគុណ





ពិធីបំពាក់មួកសុវត្ថិភាពជូនដល់កម្មករនិយោជិតដែលចូលរួមក្នុងអង្គពិធី

# ពិធីផ្សព្វផ្សាយអប់រំអំពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងផ្តល់ប័ណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានរៀបចំពិធីចែកប័ណ្ណបើកបរ និងវិញ្ញាបនបត្រជូនអ្នកបើកបរដឹកកម្មករ គ្រូពេទ្យប្រចាំរោងចក្រ រដ្ឋបាលប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋាន នៅរោងចក្រ JIUN YE GARMENT (CAMBODIA) CO.,LTD មានទីតាំងស្ថិតនៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ កម្មវិធីនេះធ្វើឡើង ក្រោមអធិបតីភាព **ឯកឧត្តម ឈួរ ច័ន្ទឌឿន** អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងតំណាងមន្ទីរ អង្គភាព ចំណុះរដ្ឋបាលសាខាខេត្ត ដោយមានសិក្ខាកាមចូលរួមជាច្រើននាក់ទៀត។


សិក្ខាកាមដែលជាកម្មករនិយោជិតចូលរួមក្នុងកិច្ចប្រជុំ

មកដល់ពេលបច្ចុប្បន្ន ប.ស.ស មានក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន រោងចក្រ ដែលជាសមាជិក ចំនួន ៨,៣២៩ និងមានបុគ្គលិក កម្មករ-កម្មការិនី ចំនួន ១,១១៣.៥៦១នាក់ ក្នុងនោះរោងចក្រកាត់ដេរមាន ១,០២៧ រោងចក្រ និងមានកម្មករ កម្មការិនី ២០៣,០៦៦នាក់។ រយៈពេល ៨ ឆ្នាំមកនេះ ប.ស.ស មានកម្មករ កម្មការិនី ដែលទទួលរងគ្រោះថ្នាក់ការងារមានចំនួន ១១៩,៩០៤ នាក់ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរចំនួន ៣២,៩៧៩នាក់ ប.ស.ស បានផ្តល់ការព្យាបាល ការថែទាំវេជ្ជសាស្ត្រ និងតាវកាលិកផ្សេងៗទៀត។

ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ជាពិសេសគ្រោះថ្នាក់ចំពោះមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត។ នៅក្នុងឆ្នាំ២០១៣កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ


ឯកឧត្តម ឈួរ ច័ន្ទឌឿន អញ្ជើញជាអធិបតីក្នុងពិធីផ្តល់មួកសុវត្ថិភាពដល់កម្មករ

បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត ដោយមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងចុះផ្សព្វផ្សាយអប់រំច្បាប់ចរាចរណ៍ ដល់បងប្អូនកម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករ។ មកដល់បច្ចុប្បន្ន ក្រុមការងារសម្រេចបានលទ្ធផលដូចខាងក្រោម៖

ចុះផ្សព្វផ្សាយអប់រំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន សុវត្ថិភាពធ្វើដំណើររបស់កម្មករនិយោជិត, បណ្តុះបណ្តាលវគ្គប្រឡងយកប័ណ្ណបើកបរ, បណ្តុះបណ្តាលគ្រូបង្គោលផ្នែកសុវត្ថិភាពចរាចរាណ៍ និងបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋម។

ដោយឡែកសម្រាប់ខេត្តកំពង់ឆ្នាំង នៅក្នុង២០១៦នេះ ក្រុមការងារបានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចំនួន ១២រោងចក្រ និងមានអ្នកចូលរួមចំនួន ១,៥៦៦នាក់ ចុះបណ្តុះបណ្តាលប្រឡងយកប័ណ្ណបើកបរជាប់ជាស្ថាពរ ១៨៥នាក់ បណ្តុះបណ្តាលគ្រូបង្គោល ផ្នែកសុវត្ថិភាពចរាចរណ៍បានចំនួន២៤ នាក់ និងបណ្តុះបណ្តាលភ្នាក់ងារសង្គ្រោះបឋមបានចំនួន ៧០ នាក់៕



ពិធីផ្តល់ប័ណ្ណសរសើរ និងមួកសុវត្ថិភាពជូនដល់កម្មករនិយោជិតដែលចូលរួមក្នុងកិច្ចប្រជុំ

# ពិធីចែកប័ណ្ណបើកបរដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ CARLINTON (CAMBODIA)CO.,LTD ស្រុកជើងព្រៃ ខេត្តកំពង់ចាម

ដូចដែលយើងដឹងស្រាប់ហើយថា គ្រោះថ្នាក់ចរាចរណ៍ នៅពេលដែលកើតឡើងហើយនោះ វានាំឱ្យខាតបង់សព្វបែបយ៉ាង ជាពិសេសអ្នកបើកបរផ្ទាល់ក៏ត្រូវប្រឈមនឹងច្បាប់ដែលត្រូវបានពិន័យ និងមានទោសទៀតផង។ ដូចនេះហើយដើម្បីជៀសវាងបញ្ហាទាំងនេះកើតឡើង ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចុះផ្សព្វផ្សាយអប់រំណែនាំ បង្រៀន និងធ្វើការប្រឡងយកប័ណ្ណបើកបរនៅតាមបណ្តារោងចក្រ សហគ្រាសដល់អ្នកបើកបរផ្ទាល់ផងដែរ។



លោកឧត្តមសេនីយ៍ត្រី លុយ ឈីន អញ្ជើញជាអធិបតីក្នុងអង្គពិធី



សិក្ខាកាមចូលរួមក្នុងអង្គពិធី

កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ ក្រុមការងារបានសហការជាមួយរោងចក្រ CARLINTON (CAMBODIA) CO.,LTD បានបើកកិច្ចប្រជុំផ្សព្វផ្សាយ និងចែកជូនប័ណ្ណបើកបរដល់អ្នកបើកបរតាមបណ្តារោងចក្រ ដែលបានប្រឡងជាប់ ក្រោមការអញ្ជើញចូលរួមជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់លោកឧត្តមសេនីយ៍ត្រី **លុយ ឈីន** អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត **លោក ជាវ ម៉ុនរិទ្ធ** តំណាង ដ៏ខ្ពង់ខ្ពស់របស់ **លោក អ៊ុក សមវិទ្យា** នាយក នៃ ប.ស.ស ដែលជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់



ពិធីផ្តល់បណ្ណបើកបរជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត

គាំពារកម្មករនិយោជិត អាជ្ញាធរដែនដីខេត្តពាក់ព័ន្ធ និងមានអ្នកបើកបរចូលរួមប្រមាណ៨៩នាក់។

ក្នុងឱកាសនោះ លោកស្រីតំណាងឱ្យរោងចក្រ CARLINTON បានឡើងមានមតិ និងកោតសរសើរ ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានអនុញ្ញាតឱ្យក្រុមការងារ សហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ បានយកចិត្តទុកដាក់ចុះបង្រៀនដើម្បីប្រលងយកប័ណ្ណបើកបរ ជាប្រយោជន៍ដើម្បីឱ្យអ្នកបើកបរផ្ទាល់គោរពច្បាប់ចរាចរណ៍ តាមរយៈការបណ្តុះបណ្តាលទាំងផ្នែកទ្រឹស្តី និងការអនុវត្តដៃចង្កូតផ្ទាល់ ក្នុងការចូលរួមចំណែកកាត់បន្ថយ គ្រោះថ្នាក់ដែលកើតឡើងជាយថាហេតុ បានដល់កម្រិតអប្បបរមា។

**លោក ជាច ប៊ុនរិទ្ធ** ប្រធានការិយាល័យ នៃប.ស.ស និងជាសមាជិកក្រុមការងារ បានឡើងមានមតិផងដែរ អំពីសារបាននៃប.ស.ស ការផ្តល់សិទ្ធិ និងសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗពី ប.ស.ស និងបានរំលេចអំពីអត្ថប្រយោជន៍ដែលកម្មករនិយោជិតទទួលបានពេញលេញនាពេលខាងមុខនេះមានដូចជា និយោជក ,កម្មករនិយោជិត និងអ្នកនៅក្នុងបន្ទុកផ្ទាល់របស់កម្មករនិយោជិតបាននឹងកំពុងទទួលបានការថែទាំសុខភាពសុខភាព (ដែលក្នុងនោះមានការបង្ការការទប់ស្កាត់ ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ និងមាតុភាពជាដើម...) និងកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់សោធននិវត្តដូចមន្ត្រីរាជការដែរ នៅពេលខ្លួនចាស់ជរាមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបំពេញការងារ។

លោក **ឧត្តមសេនីយ៍ត្រី លុយ ឈីន** អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ និងជាអនុប្រធានក្រុមការងារក៏បានមានមតិលើកឡើង និងណែនាំដល់អ្នកបើកបរ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការបញ្ជាយានយន្ត ការមិនសេពគ្រឿងស្រវឹង និងកត្តាផ្សេងៗទៀត ដែលនាំឱ្យបងប្អូនអ្នកបើកបរបណ្តាលឱ្យខ្លួនមានទោសកំហុស នាំឱ្យគ្រោះថ្នាក់ ដល់អ្នករួមដំណើរជាមួយ ការខាតប្រយោជន៍ដល់ខ្លួនឯងផ្ទាល់ និងខាតប្រយោជន៍សាធារណៈផងដែរ។

លោកបន្តទៀតថា បន្តិចទៀតក្រុមការងារ និងក្រសួងស្ថាប័នពាក់ព័ន្ធ គ្រោងនឹងបង្កើតឲ្យមានការរៀន និងប្រឡងយកប័ណ្ណបើកបរមួយប្រភេទទៀត ដែលគោលការណ៍ច្បាប់តម្រូវឱ្យមានគ្រប់គ្នាចំពោះអ្នកបើកបរទៀតផង។



ពិធីផ្តល់បណ្ណបើកបរជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត



ចុងក្រោយនៃការបិទកម្មវិធី លោកឧត្តមសេនីយ៍ត្រី បានទទូចដល់អាជ្ញាធរដែនដី មន្ទីរ/ អង្គភាពពាក់ព័ន្ធ ជួយពិនិត្យ និងជួយសម្រួលនូវសណ្តាប់ធ្នាប់ចរាចរណ៍សាធារណៈ ដល់អ្នកបើកបរតាមបណ្តារោងចក្រ សហគ្រាស ខេត្តកំពង់ចាម ឲ្យមានលក្ខណៈងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាពិសេសអ្នកបើកបរផ្ទាល់ជួយសហការណ៍ឱ្យបានស្អិតរមួត ជាបច្ច័យរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ឲ្យស្ថិតនៅកម្រិតមួយទាបដែលអាចធ្វើទៅបាន។



# ក្រុមការងារ ស.ផ.ក បានរៀបចំពិធីផ្តល់ប័ណ្ណបើកបរ និងផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ជូនដល់អ្នកបើកបរដឹកកម្មករនិយោជិត នៅរោងចក្រ QUINT MAJOR INDUSTRIAL CO.,LTD

**លោក នាង តារិទ្ធ** អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ និងជាអនុប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) តំណាង **លោក អ៊ុក សមវិទ្យា** នាយក ប.ស.ស និងជាប្រធានក្រុមការងារ ស.ផ.ក នៅព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ នេះ បានចុះចែកប័ណ្ណបើកបរ និង



សិក្ខាកាមចូលរួមក្នុងកិច្ចក្នុងអង្គពិធី

ផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកជូនដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត នៅរោងចក្រ QUINT MAJOR INDUSTRIAL CO.,LTD ស្ថិតក្នុងឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ក្នុងគោលបំណងរួមចំណែកពង្រឹងសុវត្ថិភាពចរាចរណ៍ សំដៅកាត់បន្ថយគ្រោះថ្នាក់របស់កម្មករនិយោជិត ក៏ដូចជាកាត់បន្ថយផលប៉ះពាល់



អធិបតីចូលរួមក្នុងកម្មវិធី

ក្នុងសង្គម។

**លោក នាង តារិទ្ធ** បានឱ្យដឹងថា គ្រោះថ្នាក់ចរាចរណ៍ជាឃាតករលោក់មុខ ដែលធ្វើឱ្យប្រជាពលរដ្ឋ កម្មករ-កម្មការិនី ស្លាប់បាត់បង់ជីវិតក្នុងមួយថ្ងៃពី៦ ទៅ៧នាក់ ហើយតាមរបាយការណ៍របស់ គ.ស.ច.គ ក្នុងឆមាសទី១ ឆ្នាំ២០១៦ មានករណីគ្រោះថ្នាក់ចំនួន ១,៩០០លើក មានអ្នកស្លាប់ចំនួន ៩១៩នាក់ ក្នុងនោះកម្មករនិយោជិត មានចំនួន ៤២នាក់ និងរបួស ៣,៣០៩នាក់ ដែលភាគច្រើនបណ្តាលមកពី បើកបរលើសល្បឿនកំណត់ មិនប្រកាន់ស្តាំ ស្រវឹង មិនគោរពសិទ្ធិអាទិភាព វ៉ាជែងក្នុងស្ថានភាពគ្រោះថ្នាក់។



លោក ជាវ ប៊ុនរិទ្ធ ធ្វើបទបង្ហាញអំពីអត្ថប្រយោជន៍របស់ ប.ស.ស



ពិធីផ្តល់វិញ្ញាបនប័ត្រជូនដល់តំណាងរោងចក្រ

សម្រាប់អ្នកបើកបរមិនគោរពច្បាប់ និងត្រូវទទួលពិន័យ ជាប្រាក់ ពី ៨០០,០០០រៀល ទៅ ៤,០០០,០០០រៀល និងត្រូវជាប់ពន្ធនាគារ ពី ១ខែ ទៅ ៦ខែ។

**លោក នាង ឆារិទ្ធ** បានបន្ថែមថា ចំពោះបញ្ហានេះ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ) បានសហការជាមួយក្រសួងការងារ និងក្រសួងពាក់ព័ន្ធធ្វើការអំពាវនាវផ្សព្វផ្សាយ ដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត គប្បីប្រើប្រាស់ប្រភេទរថយន្តឱ្យបានត្រឹមត្រូវ មានរថយន្តតូរីស ឬរថយន្តបីស, មិនត្រូវដាក់មនុស្សលើដំបូលរថយន្ត, រថយន្តត្រូវមានកៅអីអង្គុយឱ្យបានត្រឹមត្រូវ, អ្នកបើកបរត្រូវមានប័ណ្ណបើកបរគ្រប់គ្នា, រថយន្តត្រូវមានស្លាកលេខ មានវិញ្ញាបនបត្រត្រួតពិនិត្យ ពោលគឺទាំងអ្នកបើកបរ និងរថយន្តត្រូវតែត្រឹមត្រូវ តាមបទប្បញ្ញត្តិច្បាប់កំណត់។ចំពោះបញ្ហាប្រឈមនេះបេឡាជាតិរបបសន្តិសុខសង្គមបានសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន ចុះរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិត នៅតាមបណ្តុំរោងចក្រទូទាំង២៥រាជធានី-ខេត្ត ដែលមានអ្នកបើកបរដឹកកម្មករនិយោជិត ហើយអ្នកប្រឡងជាប់ជាស្ថាពរសរុបចំនួន ១,៣៣៩ នាក់ និងចែកប័ណ្ណបើកបរបានចំនួន ៥៣៨ប័ណ្ណ ក្នុងនោះ នៅរោងចក្រ QUINT MAJOR INDUSTRIAL CO.,LTD បានប្រឡងជាប់ជាស្ថាពរបានចំនួន ៩០នាក់។ សូមជម្រាបថា សម្រាប់គោលដៅបន្ត បេឡាជាតិរបបសន្តិសុខសង្គម និងអគ្គនាយកដ្ឋានដឹកជញ្ជូនបាននិងកំពុងបណ្តុះបណ្តាលច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរដឹកកម្មករនិយោជិត ជាបន្តបន្ទាប់ទៀតដើម្បីត្រៀមប្រឡងយកប័ណ្ណបើកបរ ស្របតាមប្រភេទយានយន្តបានចំនួន ៨៦២នាក់ ថែមទៀតផងដែរ៕





ពិធីផ្តល់ប័ណ្ណបើកបរជូន ដល់អ្នកបើកបរដឹកកម្មករនិយោជិត

# សិក្ខាសាលាលក្ខណៈទ្វេតំបន់ ស្តីពីគោលនយោបាយហិរញ្ញប្បទានសុខភាព សម្រាប់ការឈានឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកលនៅអាស៊ី

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម បានអញ្ជើញទៅចូលរួមសិក្ខាសាលាលក្ខណៈទ្វេតំបន់ ស្តីពីគោលនយោបាយហិរញ្ញប្បទានសុខភាព សម្រាប់ការឈានឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសាកលនៅអាស៊ី (Bi-Reginal Workshop on Health Financing Policy for Universal Health Coverage in Asia) នៅប្រទេសហ្វីលីពីន ដោយមានប្រទេសចូលរួមចំនួន ០៧ប្រទេសរួមមាន៖ Philppine, China, Mongoly, Banglades, Lao, Vietname and Cambodia សមាសភាពចូលរួមសរុប ៧០នាក់ ក្រោមជំនួយឧបត្ថម្ភគាំទ្រដោយអង្គការសុខភាពពិភពលោក(WHO)។



សកម្មភាពរួមនៃកិច្ចប្រជុំ

បំណង នៃសិក្ខាសាលាគឺ៖ ដើម្បីចែករំលែកបទពិសោធន៍រវាងបណ្តាប្រទេសក្នុងតំបន់ និងកិច្ចសហការរវាងបណ្តាប្រទេសពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធផ្សេងៗ, វិភាគ និងស្វែងរកបញ្ហាប្រឈម នៃប្រទេសមួយៗទាក់ទង និងហិរញ្ញប្បទានសុខាភិបាល និងការកំណត់ការរៀបចំគោលនយោបាយ នៃប្រទេសនិមួយៗឱ្យមានសក្តានុពលទាក់ទង និងដំណើរឈានឆ្ពោះទៅរកការគ្របដណ្តប់សុខភាពសាកល។





កិច្ចពិភាក្សាជាក្រុមដើម្បីចែករំលែកបទពិសោធន៍រវាងបណ្តាប្រទេសក្នុងតំបន់

# កិច្ចប្រជុំផ្សព្វផ្សាយអំពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ នៅរោងចក្រ GOLDFAME STAR ENTERPRISES (CAMBODIA) LIMITED

កាលពីព្រឹកថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារបានបើកកិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពី លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ, អត្ថប្រយោជន៍របបសន្តិសុខសង្គម, សុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និង នីតិវិធីដោះស្រាយវិវាទការងារ នៅរោងចក្រ GOLDFAME STAR ENTERPRISES (CAMBODIA) LIMITED ក្រោមការដឹកនាំរបស់ **លោក ផេង សុវណ្ណា** មន្ត្រីការិយាល័យគោលនយោបាយនៃបេឡាជាតិរបបសន្តិសុខសង្គម **លោក សោម និស្ស័យ** ប្រធានផ្នែកស្រាវជ្រាវព័ត៌មានបណ្តុះបណ្តាល និងចលនាមហាជននៃអគ្គលេខាធិការដ្ឋាន គណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា (អ.គ.ក.ប) **លោក អឿ ទី** ប្រធានការិយាល័យ នៃ (អ.គ.ក.ប) និង **លោក ឯក សុខជា** មន្ត្រី នៃ (អ.គ.ក.ប) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងមានការចូលរួមពីតំណាងសហគ្រាស និងកម្មករនិយោជិត។

ជាកិច្ចប្រជុំធ្វើឡើងក្នុងគោលបំណងចុះអប់រំដល់កម្មករនិយោជិត ឲ្យយល់ដឹងកាន់តែច្បាស់អំពីលក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ, លក្ខខណ្ឌការងារ, អត្ថប្រយោជន៍របបសន្តិសុខសង្គម, សុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត និងនីតិវិធីដោះស្រាយវិវាទការងារ ។




អធិបតីចូលរួមក្នុងកិច្ចប្រជុំ

ជាកិច្ចបញ្ចប់ក្រុមការងារបានមានមតិផ្តាំផ្ញើចំពោះបងប្អូនកម្មករនិយោជិត ដែលបានចូលរួមនាពេលនេះ សូមយកចំណេះដឹងដែលទទួលបានទៅចែករំលែកដល់អ្នករួមការងារ ដែលមិនបានចូលរួមនាពេលនេះ ហើយសូមជៀសវាងការធ្វើកូដកម្ម បាតុកម្ម ព្រោះរោងចក្រជាផ្ទាំងបាយរបស់យើងទាំងអស់គ្នា ដើម្បីធ្វើឲ្យបានប្រសើរឡើងនូវជីវភាពរស់នៅទាំងអស់គ្នា។





សិក្ខាកាមដែលជាកម្មករនិយោជិតចូលរួមក្នុងកិច្ចប្រជុំ

# កម្មការិនីនៅរោងចក្រ GRAND EAST FOODWEAR INT'L CORP សន្លប់ ៨៩នាក់ ផ្ដើមចេញពីកម្មការិនីម្នាក់មានអាការៈមិនស្រួលខ្លួនបានសន្លប់ បន្ទាប់មកកម្មការិនីផ្សេងទៀតភិតភ័យក៏សន្លប់តៗគ្នា

កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង៦ និង៣០នាទីព្រឹក នៅរោងចក្រ ផលិតស្បែកជើង (Grand East Footwear INT'L Corp) ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ០៤ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល មានករណីកម្មការិនីប្រមាណ ៨៩ នាក់ បានសន្លប់។ ភ្លាមៗនោះរោងចក្រ ក៏បានផ្អាកសកម្មភាពផលិតកម្ម រួចបញ្ជូនជនរងគ្រោះទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកអង្គស្នួលចំនួន ៣៨នាក់ និងគ្លីនិកសុខាបែកចានចំនួន ៥១នាក់។

មូលហេតុដែលបង្កឱ្យមានកម្មការិនីសន្លប់រហូត ៨៩នាក់ខាងលើ គឺផ្ដើមចេញពីកម្មការិនីម្នាក់ឈ្មោះ ខា ស្រីនាង អាយុ ២០ឆ្នាំ ធ្វើការផ្នែកដេរ មានអាការៈមិនស្រួលខ្លួន នៅពេលដំបូងមិនទាន់បានបំពេញកាងារហើយក៏ងងឹតមុខដួលនៅកន្លែងធ្វើការតែម្ដង។ បន្ទាប់មកកម្មការិនីផ្សេងទៀតឃើញហេតុការណ៍នេះ ក៏មានការភិតភ័យបណ្ដាលឱ្យសន្លប់តៗគ្នារហូត ដល់ចំនួន ៨៩នាក់ ក្នុងនោះសុទ្ធតែជាកម្មការិនីទាំងអស់។

ហេតុការណ៍នេះដែរក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានចុះអង្កេតសិក្សាស្រាវជ្រាវរកមូលហេតុកម្មករសន្លប់ដែលបានកើតឡើង ព្រមទាំងធ្វើការត្រួតពិនិត្យវាស់ស្ទង់ទាំងក្នុង និងក្រៅរោងចក្រ ក្រុមការងារសង្កេតឃើញថាមូលហេតុដែលបណ្ដាលឱ្យកើតមានករណីសន្លប់ខាងលើនេះបណ្ដាលមកពី៖ មិនបានញ៉ាំអាហារពេលព្រឹកមុនពេលចូលធ្វើការ និងដោយសារគាត់ឧស្សាហ៍មានជំងឺផ្ទាល់ខ្លួន, ខាងរោងចក្រមិនបានបំពាក់ប្រព័ន្ធកង្ហារនៅតាមជញ្ជាំងអាគារផលិតកម្ម។





កិច្ចពិភាក្សារកមូលហេតុដែលធ្វើឱ្យកម្មករសន្លប់



សកម្មភាពរបស់ក្រុមការងារចុះត្រួតពិនិត្យកន្លែងសង្វាក់ផលិតកម្ម

ក្រោយពីបានធ្វើការត្រួតពិនិត្យរកឃើញពីមូលហេតុនេះ ក្រុមការងារបានចាត់វិធានការចំពោះរោងចក្រ ត្រូវធ្វើការកែលំអមួយចំនួនដូចជា៖ រៀបចំបង្កើតឱ្យមានប្រព័ន្ធកង្ហារបឺតខ្យល់នៅតាមជញ្ជាំង និងបើកប្រព័ន្ធកង្ហារមុនពេលកម្មករចូលធ្វើការ ឱ្យបានមុនកន្លះម៉ោងរៀងរាល់ថ្ងៃធ្វើការ, ការប្រើប្រាស់ការត្រូវមានគម្របគ្របជិតដើម្បីធានាថាមិនមានការសាយភាយក្លិនដល់ផ្លូវដង្ហើម ដល់កម្មករនិយោជិត, អប់រំកម្មករនិយោជិតស្ដីអំពីហូបចំណីអាហារឱ្យបានទៀងទាត់ និងមានអនាម័យ, ផ្អាកការបន្ថែមម៉ោងមួយរយៈរហូតដល់សុខភាពកម្មករនិយោជិត វិលមករកស្ថានភាពសុខភាពល្អឡើងវិញទើបអនុញ្ញាតឱ្យមានការធ្វើការថែមម៉ោង ដោយគោរពតាមគោលការណ៍ច្បាប់ស្ដីពីការងារ។

# កម្មករ-កម្មការិនីប្រមាណ ៣៣នាក់ ទទួលរងគ្រោះថ្នាក់ចរាចរណ៍បង្កដោយរថយន្តដឹកកម្មករបានគេចរថយន្តដឹកថ្ម ដែលបើកឆ្លងផ្លូវក្នុងល្បឿនលឿនបណ្តាលឱ្យក្រឡាប់ចាក់កម្មករទៅលើផ្លូវ

មានករណីគ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកកម្មករពាក់ស្លាក់លេខ 2A-3787 បានក្រឡាប់ផ្ងារជើង បណ្តាលឱ្យកម្មកររងរបួសចំនួន ៣៣នាក់ ធ្ងន់០៦នាក់ និងស្រាល ២៧នាក់ កាលពីវេលាម៉ោង០៦:១៥ព្រឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦នេះ នៅចំណុចភូមិក្រាំងក្រូច ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

មុនពេលកើតហេតុ រថយន្តម៉ាកហ៊ីយ៉ានដាយ បើកដឹកកម្មករទិសដៅពីជើងទៅត្បូង លុះដល់ចំណុចកើតហេតុ រថយន្តដឹកកម្មករបានគេចរថយន្តដឹកថ្ម ដែលបើកឆ្លងផ្លូវក្នុងល្បឿនលឿនបណ្តាលឲ្យក្រឡាប់ចាក់កម្មករទៅលើផ្លូវតែម្តង។

ហេតុការណ៍គ្រោះថ្នាក់ខាងលើ មន្ត្រី ប.ស.ស ខេត្ត បានចុះទៅដល់កន្លែងកើតហេតុ ធ្វើការសម្របសម្រួលបញ្ជូនជនរងគ្រោះទៅសង្គ្រោះបន្ទាន់នៅ គ្លីនិកសុខាបែកចានចំនួន ១៦នាក់, គ្លីនិកថ្នល់ទទឹងចំនួន ១១នាក់, បញ្ជូនបន្តទៅមន្ទីរពេទ្យកាល់ម៉ែត ០៣នាក់ និងមន្ទីរពេទ្យព្រះកុសុមៈ ចំនួន ០៣នាក់។ ចំពោះរាល់ការចំណាយលើសេវាដឹកជញ្ជូន និងថ្លៃសេវាព្យាបាលជនរងគ្រោះរហូតជាសះស្បើយ ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ៕



សកម្មភាពនៃការចុះទៅសួរសុខទុក្ខជនរងគ្រោះនៅមន្ទីរពេទ្យ







# បុរសម្នាក់ជិះម៉ូតូចេញពីធ្វើការបានជ្រុលចង្កូតទៅបុកជាមួយរថយន្ត ដឹកកម្មករបណ្តាលឱ្យរងរបួសដាច់ស្បែកជង្គង់ខាងឆ្វេង

គ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតឡើងជារៀងរាល់ថ្ងៃ បានបណ្តាលឲ្យមានអ្នកស្លាប់ របួស ដែលបានបន្សល់ទុកនូវសោកនាដកម្មដ៏រន្ធត់បំផុត ចំពោះឧបទ្ទវហេតុដែលកើតឡើងនេះ។ ព្រមទាំងបាត់បង់ធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ជាតិ ខាតបង់ថវិការដ្ឋ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ និងបានបន្សល់ទុកនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគត់ជនជាច្រើននាក់។



កាលពីថ្ងៃទី០៤ខែកក្កដា ឆ្នាំ២០១៦ នៅវេលាម៉ោងប្រមាណ ០៤និង៥០នាទីរសៀលមានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងលើកម្មករឈ្មោះ យ៉ាង គីមហៀក ភេទប្រុស អាយុ២៥ ឆ្នាំ ជាកម្មករបម្រើការងារនៅក្នុងក្រុមហ៊ុន ឡុងស្រេង អ៊ិនធឺណេសេនណល់ មានទីតាំងស្ថិតនៅភូមិបឹងកេត ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ខណៈពេលដែលកំពុងជិះម៉ូតូចេញពីធ្វើការត្រឡប់មកផ្ទះ លុះមកដល់ចំណុចកើតហេតុបានជ្រុលចង្កូតទៅបុកជាមួយរថយន្តដឹកកម្មករ បណ្តាលឱ្យរបួសដាច់ស្បែកជង្គង់ខាងឆ្វេង នៅត្រង់ចំណុចផ្លូវបំបែកឡើកៅស៊ូ១២ ភូមិមាយ ឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។



ចំណែកឯជនរងគ្រោះត្រូវបានក្រុមហ៊ុនបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម ចំពោះការចំណាយលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាល ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

រាជរដ្ឋាភិបាល ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គម និងក្រសួងដែលពាក់ព័ន្ធ បានអំពាវនាវដល់បងប្អូនកម្មករ-កម្មការិនី និងប្រជាពលរដ្ឋនៅក្នុងប្រទេស ឱ្យធ្វើដំណើរដោយគោរពច្បាប់ចរាចរណ៍ ឱ្យមានការប្រុងប្រយ័ត្នក្នុងការបើកបរ ដើម្បីកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ស្របទៅនឹងសម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា "**ថ្ងៃនេះថ្ងៃស្អែកសុំកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍**" ៕



*ស្ថានភាពរបស់ជនរងគ្រោះដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ*

# យ៉ាងហោចណាស់កម្មការិនី ១២នាក់ បានរងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ រវាងរថយន្តដឹកកម្មករ២គ្រឿងបុកគ្នានៅខេត្តស្វាយរៀង



គ្រោះថ្នាក់ចរាចរណ៍នៅតែបន្តកើតឡើងស្ទើរជារៀងរាល់ថ្ងៃ បានបណ្តាលឲ្យមានអ្នកស្លាប់ និងរបួសដែលបានបន្សល់ទុកនូវសោធនាដកម្មដ៏រន្ធត់បំផុតចំពោះឧបទ្ទវហេតុដែលកើតឡើងនេះ។ ព្រមទាំងបាត់បង់ធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ជាតិ ខាតបង់ថវិការរដ្ឋ ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ និងបានបន្សល់ទុកនូវកុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ និងទុរគត់ជនជាច្រើននាក់។

កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ នៅវេលាម៉ោងប្រមាណ ០៥ និង ១០នាទីរសៀល មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងនៅតាមបណ្តោយផ្លូវជាតិលេខ១ចន្លោះគីឡូម៉ែត្រ ១៩៧-១៩៨ ត្រង់ចំណុចភូមិថ្នល់ជាតិ សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង។ ហេតុការណ៍គ្រោះថ្នាក់នេះដែរបានកើតឡើងខណៈពេល ដែលរថយន្តដឹកកម្មករមួយគ្រឿងពាក់ស្លាកលេខ (3A-0272) បើកចេញពីតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន លុះដល់ចំណុចកើតហេតុបានជ្រុលចង្កូតទៅបុករថយន្តដឹកកម្មករមួយគ្រឿងទៀតពីខាងក្រោយបណ្តាលឱ្យកម្មការិនីទទួលរងរបួសធ្ងន់ និងស្រាលរហូតដល់ ១២នាក់។

ហេតុការណ៍គ្រោះថ្នាក់នេះដែរ មន្ត្រីសាខា ប.ស.ស ខេត្ត បានចុះជួយសម្របសម្រួលបញ្ជូនជនរងគ្រោះទៅសម្រាកព្យាបាលនៅមន្ទីពេទ្យបង្អែកជីភូ និងមន្ទីរពេទ្យខេត្តស្វាយរៀង។ ចំពោះការចំណាយលើមធ្យោបាយដឹកជញ្ជូន និងសេវាព្យាបាល ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

រាជរដ្ឋាភិបាល ក៏ដូចជាបេឡាជាតិរបបសន្តិសុខសង្គម និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ បានអំពាវនាវ ដល់បងប្អូនដឹកកម្មករ-កម្មការិនី និងប្រជាពលរដ្ឋទាំងអស់ ឲ្យធ្វើដំណើរដោយគោរពច្បាប់ចរាចរណ៍ ឲ្យមានការប្រុងប្រយ័ត្នទ្វេរដង ក្នុងការបើកបរ ដើម្បីកុំអោយមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ស្របទៅនឹងសម្តេចតេជោហ៊ុនសែន បានមានប្រសាសន៍ “ថ្ងៃនេះថ្ងៃស្អែកកុំឲ្យមានគ្រោះថ្នាក់ចរាចរណ៍” ៕





សកម្មភាពរបស់គ្រូពេទ្យកំពុងព្យាបាលជនរងគ្រោះដែលទទួលរងគ្រោះថ្នាក់នៅខេត្តស្វាយរៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ..........១០៩..........ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# គាំទភាពិកថៃទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៤៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់តាវកាលិកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ៖

- *តាវកាលិកថែទាំសុខភាព* សំដៅដល់របបធានារ៉ាប់រង ដែលផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការដែលបានកំណត់។
- *កញ្ចប់តាវកាលិកសុខភាព* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឲ្យមានបញ្ហាសុខភាពមានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។
- *សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា។
- *បច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ* សំដៅដល់វិធីសាស្ត្រ នៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់សេវាព្យាបាលថែទាំ ដែលផ្តល់ដោយអ្នកបញ្ចប់ការសិក្សាក្នុងវិស័យសុខាភិបាល ហើយត្រូវបានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈពេទ្យ និងត្រូវបានអនុញ្ញាតច្បាប់ឲ្យប្រកបមុខរបរតាមវិជ្ជាជីវៈ ដោយក្រសួងសុខាភិបាល។
- *សេវាស្តារនីតិសម្បទា* គឺជាសេវាព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។
- *សម្រាកមាតុភាព* សំដៅដល់ការសម្រាកមុន និងក្រោយពេលសម្រាលកូន។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺក្រៅ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។

**ប្រការ ៣.-**

តាវកាលិកថែទាំសុខភាព មានការផ្ដល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការសុខភាពដែលបានកំណត់ ។

៣.១ កញ្ចប់តាវកាលិកសុខភាព

កញ្ចប់តាវកាលិកសុខភាព មានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។

ក. សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

ក.១. ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និង សម្ភារបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (ធម្មតា) និងអាហារដែលផ្ដល់ដោយមូលដ្ឋានសុខាភិបាល។

ក.២. សេវាពិគ្រោះជំងឺក្រៅ

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ រូបភាពវេជ្ជសាស្ត្រ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

ក.៣. សេវាសង្គ្រោះបន្ទាន់

សេវាសង្គ្រោះបន្ទាន់ គឺជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬ ជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ។

ក.៤. សេវាព្យាបាលដោយស្ពំ និងដោយចលនា។

ក.៥. សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និង ក្រោយពេលសម្រាល
កូន។

ក.៦ សេវាស្តារនីតិសម្បទា

សេវាស្តារនីតិសម្បទា ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬ ស្ថាប័ន និងអង្គការទាក់ទងទៅនឹងការស្តារ នីតិសម្បទាដទៃទៀត។

ខ. សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព។

គ. ប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវបានផ្តល់ជូនក្នុងពេលមានជំងឺ ឬជួបឧបទ្ទវហេតុផ្សេងៗ ដោយគិតបញ្ចូលទាំងចំណុច១ ក្នុងប្រការ៤ នៃប្រកាសនេះ។

៣.២ សេវាបង្ការសុខភាព

សេវាបង្ការសុខភាព ផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត។

**ប្រការ ៤.-**

សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្រគឺ៖

១. ការព្យាបាលដោយមិនគិតថ្លៃដែលមានចែងនៅក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

៣. ការព្យាបាល និងការវះកាត់ប្តូរភេទ

៤. ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ

៥. សេវាបង្កកំណើតដោយសិប្បនិម្មិត

៦. ការព្យាបាលដោយខ្លួនឯង

៧. ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន

១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត

១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង

១៣. ការលាងឈាម

១៤. ការព្យាបាលមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើត្រូវបានផ្តល់ជូន។

**ប្រការ ៥.-**

ការផ្តល់សេវាចំពោះជំងឺពុំរ៉ៃត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ នឹងត្រូវប្រើប្រាស់តែឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុកផ្ទាល់របស់អ្នកជំងឺ។

**ប្រការ ៦.-**

៦.១ ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់របបថែទាំសុខភាព
- បានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
- បានបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាពក្នុងរយៈពេល ០២(ពីរ)ខែ ជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច ០៦(ប្រាំមួយ)ខែ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។

ក្នុងករណីដែលសមាជិកបានបង់ភាគទាន ០២(ពីរ)ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានដោយសារការបញ្ចប់កិច្ចសន្យាការងារ សមាជិកមានសិទ្ធិទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយៈពេល ០២(ពីរ)ខែថែមទៀត គិតចាប់ពីកាលបរិច្ឆេទ នៃការបញ្ចប់កិច្ចសន្យាការងាររបស់សាមីជន។

៦.២ ដើម្បីទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- ប្រាក់បំណាច់ប្រចាំថ្ងៃជាប្រាក់ដែលផ្តល់ជូនសម្រាប់រយៈពេលអាក់ខានការងារដោយសារការធ្លាក់ខ្លួនមានជំងឺ គ្រោះថ្នាក់ និងលំហែមាតុភាព
- បានបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងចំណុច ៦.១ នៃប្រការនេះ
- ត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជកតាមទម្រង់ដែលកំណត់ដោយ ប.ស.ស
- បានបង់ភាគទានយ៉ាងតិច ០៤(ប្រាំបួន)ខែ ជាប់គ្នាចំពោះប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាព។

**ប្រការ ៧.-**

៧.១ កម្មករនិយោជិតដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៦.១ និង ៦.២ ក្នុងប្រការ៦ នៃប្រកាសនេះមានសិទ្ធិទទួលបាន៖

- ការព្យាបាលដោយឥតគិតថ្លៃនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) លើកលែងតែសេវាព្យាបាលដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ក្នុងរយៈពេលមិនលើសពី ១៨០ (មួយរយប៉ែតសិប)ថ្ងៃ ក្នុងអំឡុងពេល ១២ (ដប់ពីរ) ខែ ដោយគិតទាំងរយៈពេលព្យាបាលដោយសម្រាក នៅក្នុងមន្ទីរពេទ្យ និងមិនសម្រាកក្នុងមន្ទីរពេទ្យ។
- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេលអាក់ខានការងារ ដោយសារការសម្រាក

ព្យាបាលថែទាំជំងឺ ឬ របួស តាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧ (ប្រាំពីរ)ថ្ងៃ ។

- ប្រាក់ឈ្នួលពីនិយោជក ក្នុងករណីដែលការអាក់ខានធ្វើការងារ ដោយការឈប់សម្រាកព្យាបាលថែទាំជំងឺ ឬរបួសតាមវេជ្ជបញ្ជា ដែលមានរយៈពេលជាប់គ្នាត្រឹម ០៧ (ប្រាំពីរ)ថ្ងៃចុះ។
- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេល ៩០(កៅសិប)ថ្ងៃ នៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន។

៧.២ សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងបញ្ជូនសពៈ

- សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះត្រូវបានផ្ដល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។
- សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរដែលមិនអាចព្យាបាលឲ្យជា ឬ សពផ្ដល់ជូនទៅតាមតម្លៃមូលដ្ឋានសុខាភិបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៨.-**

៨.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទាន ក្នុងរយៈពេល ០៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទមានបញ្ហាសុខភាព។ ប្រាក់ឈ្នួលជាប់ភាគទានត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

៨.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យម ដូចមានចែងក្នុងចំណុច ៨.១ នឹង៣០(សាមសិប)ថ្ងៃ។

៨.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ។

**ប្រការ ៩.-**

៩.១ សមាជិក ប.ស.ស ត្រូវបង្ហាញអត្តសញ្ញាណដែលកំណត់ដោយ ប.ស.ស (ស្នាមម្រាមដៃ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអេឡិចត្រូនិច ឬ ប័ណ្ណសំគាល់សមាជិកភាពរបស់ ប.ស.ស)។

៩.២ ក្នុងករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស ជនរងគ្រោះ ឬអ្នកតំណាងត្រូវជូនដំណឹងបន្ទាន់ដល់ ប.ស.ស។

៩.៣ ប.ស.ស នឹងទូទាត់សងលើចំណាយសម្រាប់ការព្យាបាលសង្គ្រោះបន្ទាន់ទៅឲ្យជនរងគ្រោះ ឬ មន្ទីរពេទ្យ ដែលបានទទួលព្យាបាលសមាជិកប.ស.ស ឈរលើមូលដ្ឋានកំរិតផ្ដល់សេវា គុណភាព តម្លៃករណី និងតម្លៃសេវាដូចមានចែងនៅក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងស្ដីពីយន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព។

**ប្រការ ១០.-**

១០.១ សមាជិក ប.ស.ស ត្រូវទៅប្រើប្រាស់សេវាសុខាភិបាល នៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។ បេឡាជាតិរបបសន្តិសុខសង្គម នឹងទទួលខុសត្រូវទូទាត់ថ្លៃសេវាដូចមានកំណត់ក្នុងកញ្ចប់តាវកាលិកសុខភាព។ ប្រសិនបើសមាជិក ប.ស.ស ទៅប្រើប្រាស់សេវាក្រៅពី មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស នោះ ប.ស.ស នឹងទូទាត់សងវិញតែក្នុងករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។ ការទាមទារតាវកាលិក ត្រូវធ្វើតាមទម្រង់ "**តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ**" ឬហៅថាទម្រង់ "៥.០២" ដូចមានចែងក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះ ត្រូវមានភ្ជាប់ជាមួយនូវឯកសារវេជ្ជសាស្ត្រ និង វិក្កយបត្រនានាព្រមទាំងឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។

១០.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវធ្វើឡើងដោយអ្នកជំងឺ ឬជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់ "**ប្រាក់បំណាច់ប្រចាំថ្ងៃ**" ឬហៅថាទម្រង់ "៥.០៣" ដូចមានចែងក្នុង**ឧបសម្ព័ន្ធ៣** នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះ ត្រូវមានភ្ជាប់ជាមួយនូវលិខិតចេញពីមន្ទីរពេទ្យដែលចេញដោយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដែលជនរងគ្រោះបានចូលទៅទទួលសេវាថែទាំព្យាបាល ។ លិខិតអនុញ្ញាតច្បាប់អាចចេញ ដោយគ្រូពេទ្យសហគ្រាស ដោយមានការយល់ព្រមពីនិយោជក ឬ អ្នកតំណាងសហគ្រាស គ្រឹះស្ថាននោះ។

១០.៣ សិទ្ធិនៃការទាមទារតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងប្រាក់បំណាច់ប្រចាំថ្ងៃមានអាជ្ញាយុកាលត្រឹមរយៈពេល ១២ (ដប់ពីរ)ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាពដំបូង។

**ប្រការ ១១.-**

១១.១ សេវាបង្ការសុខភាពដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គមត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

១១.២ ប្រភេទសេវាដែលមិនរាប់បញ្ចូល ដូចដែលមានចែងនៅក្នុងប្រការ៤ នៃប្រកាសនេះ អាចនឹងត្រូវបានពិនិត្យកែសម្រួលឡើងវិញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

១១.៣ បញ្ជីជំងឺរ៉ាំរ៉ៃដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

១១.៤ សេវាស្តារនីតិសម្បទា ដូចមានចែងក្នុងប្រការ៣ ត្រង់ចំណុច ក.៦ នៃប្រកាសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ។

